ប្រការ ៤ :

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាមី រដ្ឋមន្ត្រីនៃក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ហ៊ុន សែន

★★★

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០០

## សេចក្តីសម្រេចលេខ ៥៧ សសរ

## ស្តីពីការបង្កើតគណៈកម្មការបង្ក្រាបបទល្មើសនានានិង ត្រួតពិនិត្យការពារការធ្វើនេសាទក្នុងដែនសមុទ្រខេត្តកោះកុង និងតាមបណ្តោយព្រំដែនសមុទ្រកម្ពុជា-ថៃ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីប្រកាស លេខ ០១ ប្រក ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាល ស្តីពីវិធានការគ្រប់គ្រង និងលុបបំបាត់ភាពអនាធិបតេយ្យក្នុងវិស័យព្រៃឈើ
- បានឃើញសេចក្តីប្រកាសលេខ ០២ ប្រក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាល ស្តីពីវិធានការគ្រប់គ្រង និងលុបបំបាត់ភាពអនាធិបតេយ្យក្នុងវិស័យជលផល
- បានឃើញសេចក្តីសម្រេចលេខ ១៨ សសរ ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០០ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតគណៈកម្មការចម្រុះអន្តរក្រសួង ដើម្បីបង្ក្រាបបទល្មើសអនាធិបតេយ្យក្នុងវិស័យជលផល នៃដែនសមុទ្រកម្ពុជា

- បើយោងតាមសំណើរបស់លោកអភិបាលខេត្តកោះកុង
- បានឆ្លងតាមការប្រជុំពិភាក្សាអន្តរក្រសួង នាថ្ងៃទី២២ ខែសីហា ឆ្នាំ២០០០ នៅសាលាខេត្តកោះកុង

ជាអាទិ៍ សំរេច

ប្រការ ១ :

បង្កើតគណៈកម្មការចំរុះ ដើម្បីបង្រ្កាបបទល្មើសនានា និងត្រួតពិនិត្យការពារការធ្វើនេសាទក្នុងដែនសមុទ្រខេត្តកោះកុង និងតាមបណ្តោយព្រំដែនសមុទ្រកម្ពុជា ថៃ ដូចមានសមាសភាពខាងក្រោម :

-លោកស្រី យុទ្ធ ភូថង អភិបាលខេត្តកោះកុង ប្រធាន
-លោក សាយ ឈុំ អភិបាលរងទី ១ ខេត្តកោះកុង អនុប្រធាន
-លោកឧត្តមនាវីត្រី ទៀក ស៊ីថា មេបញ្ជាការរងកងនាវាចរនិងជាមេបញ្ជាការមូលដ្ឋានសមុទ្រ អនុប្រធាន
-លោកឧត្តមសេនីយ៍ត្រី ថាំ សាន អនុប្រធាននាយកដ្ឋានព្រំដែនទឹកក្រសួងមហាផ្ទៃ អនុប្រធាន
-លោក ពុំ ស៊ីថា ប្រធានស្នាក់ការជលផលដែនសមុទ្រ អនុប្រធាន
-លោកវរសេនីយ៍ឯក ជុំ សាខុន មេបញ្ជាការស្រាវជ្រាវប្រចាំសមុទ្ររបស់អគ្គនគរបាលជាតិ សមាជិក
-លោកមេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្តកោះកុង សមាជិក
-លោកមេបញ្ជាការកងរាជអាវុធហត្ថខេត្តកោះកុង សមាជិក
-លោកស្នងការនគរបាលខេត្តកោះកុង សមាជិក
-លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកោះកុង សមាជិក
-លោកប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកោះកុង សមាជិក
-លោកប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តកោះកុង សមាជិក
-លោកប្រធានមន្ទីរពាណិជ្ជកម្មខេត្តកោះកុង សមាជិក
-លោកប្រធានសាខាគយ និងរដ្ឋាករខេត្តកោះកុង សមាជិក
-លោកប្រធានសាខាកាំកុងត្រូលប្រចាំខេត្តកោះកុង សមាជិក

ប្រការ ២ :

គណៈកម្មការនេះមានភារកិច្ច :

-បង្រ្កាបការធ្វើនេសាទអនាធិបតេយ្យ និងការពារការធ្វើនេសាទស្របច្បាប់របស់ប្រជាពលរដ្ឋ
-បង្រ្កាបការដឹកជញ្ជូនផល អនុផលព្រៃឈើ និងឈើកែច្នៃគ្រប់ប្រភេទដែលគ្មានច្បាប់អនុញ្ញាត ពីក្រសួង ស្ថាប័ន មានសមត្ថកិច្ច
-បង្រ្កាបការដឹកជញ្ជូនទំនិញរត់គេចពន្ធ គ្រឿងញៀន និងបទល្មើសនានា

-រកអោយឃើញ និងលើកសំណើដើម្បីមានវិធានការដាក់វិន័យយ៉ាងតឹងរឹងចំពោះក្រុម ឬជនខិលខូច ដែលបង្ខំទារប្រាក់ពីអ្នកធ្វើអាជីវកម្មស្របច្បាប់ដែលបានបង់ពន្ធ និងអាករផ្សេងៗ ជូនរដ្ឋរួចហើយ

-ធ្វើការបែងចែកប្រភេទ និងគ្រប់គ្រងយានយន្ត ជលយានយន្ត ដែលធ្វើអាជីវកម្មដឹកជញ្ជូនអ្នកដំណើរទំនិញ និងនេសាទ ហើយនិងយានយន្ត ជលយានយន្ត ដែលប្រើប្រាស់ផ្ទាល់របស់ប្រជាពលរដ្ឋក្នុងដែនដី និងដែនសមុទ្រខេត្តកោះកុង

-សហការ និងធ្វើទំនាក់ទំនងជាមួយ ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសថៃ ស្តីពីការគ្រប់គ្រងលើការធ្វើអាជីវកម្មនេសាទ និងបញ្ហាពាក់ព័ន្ធផ្សេងទៀតលើដែនសមុទ្រកម្ពុជា - ថៃ និងក្នុងតំបន់ត្រួតគ្នា នៃសមុទ្ររវាងកម្ពុជា - ថៃ

-ពិភាក្សាដោះស្រាយទំនាស់នានាជាមួយភាគីថៃ ដោយមិត្តភាព និងសន្តិវិធី

-អនុវត្តភារកិច្ចផ្សេងទៀតដែលប្រមុខរាជរដ្ឋាភិបាលប្រគល់អោយ

-រាយការណ៍អំពីលទ្ធផលការងារ តាមករណីជាក់ស្តែងនីមួយៗ និងធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់គណៈកម្មការនេះប្រចាំខែអោយបានទៀងទាត់ជូនប្រមុខរាជរដ្ឋាភិបាល ព្រមទាំងចម្លងជូនក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និងក្រសួងពាក់ព័ន្ធផ្សេងទៀង ។

ប្រការ ៣ :

គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់មធ្យោបាយ និងកំលាំងរបស់គណៈបញ្ជាការឯកភាពខេត្ត កងនាវាចរដែនសមុទ្រកងទ័ពជើងទឹកនៃកងយោធពលខេមរភូមិន្ទ និងកងនគរបាលការពារព្រំដែនទឹកនៃអគ្គនាយកដ្ឋាននគរបាលជាតិដែលមានស្រាប់នៅនឹងកន្លែង ។

កំលាំងដែលធ្វើសកម្មភាពបង្ក្រាបបទល្មើស ត្រូវស្ថិតក្រោមការដឹកនាំផ្ទាល់ពីប្រធានគណៈកម្មការ និងស្ថិតក្នុងរង្វង់ដែនសមុទ្រនៃខេត្តកោះកុង និងតាមបណ្តោយព្រំដែនសមុទ្រកម្ពុជា - ថៃ ។

ចំពោះបទល្មើសដែលចាប់ហោត់បាន គឺអាស្រ័យដោយសមត្ថកិច្ចជំនាញសាមីនីមួយៗជាអ្នករៀបចំកសាងសំណុំរឿងបញ្ជូនទៅតុលាការវិនិច្ឆ័យតាមច្បាប់ជាធរមាន ។

ប្រការ ៤ :

គណៈកម្មការនេះ មានសិទ្ធិបង្កើតលេខាធិការដ្ឋានមួយសំរាប់ជំនួយការងារជាអចិន្ត្រៃយ៍ ដែលមានទីស្នាក់ការកណ្តាលនៅសាលាខេត្តកោះកុង និងមានសាខាទីស្នាក់ការនៅកោះស្តេច និងកោះពាង សំរាប់ជំនួយការ ក្នុងការផ្តល់ពត៌មាន និងទទួលបទបញ្ជាផ្សេងៗពីទីស្នាក់ការកណ្តាល ។

គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់សាលាខេត្តកោះកុង ។